
វិញ្ញាណកធានី
Sensing the Capital

*វិញ្ញាណកធានី* គឺជាគម្រោងពហុពិព័រណ៍និងព្រឹត្តិការណ៍មួយ ដែលលើកឡើងនូវគំនិតសំខាន់ពីរគឺៈ «វិញ្ញាណ» និង «ធានី» ជាវិធីសាស្ត្រក្នុងការអង្កេត និងស្វែងយល់ពីរាជធានីភ្នំពេញ ព្រមទាំងធនធាននានាដែលប្រសព្វគ្នានៅក្នុង និងឆ្លងកាត់ព្រំដែនទីក្រុងនេះ តាមរយៈមធ្យោបាយចម្រុះដូចជា សិល្បៈ វប្បធម៌ ស្ថាបត្យកម្ម និងនគរោបនីយកម្ម ដើម្បីភ្ញោចនិងប្រើប្រាស់វិញ្ញាណរបស់ទស្សនិកជន និងទីក្រុង។

ខណៈពេលដែលប្រទេសកម្ពុជាប្រកាន់នូវការរៀបចំទីក្រុងបែបទីផ្សារសេរី និងចូលរួមក្នុងសេដ្ឋកិច្ចនៃសកលភាវូបនីយកម្ម ភ្នំពេញបានផ្លាស់ប្តូរយ៉ាងឆាប់រហ័សប្រកបដោយអតុល្យភាព ក្នុងនោះមានរូបរាងនិងរចនាសម្ព័ន្ធរបស់ខ្លួន ចំណាកស្រុកនិងកំណើនប្រជាជនក្នុងក្រុង ក៏ដូចជាប្រព័ន្ធអេកូឡូស៊ីបរិស្ថានជាដើម ។ គ្រាន់តែជាងមួយទសវត្សរ៍ចុងក្រោយនេះប៉ុណ្ណោះ ភ្នំពេញមានកំណើនអគារខ្ពស់ៗ ផ្សារទំនើប អគារលំនៅដ្ឋានច្រើនជាន់ និងបុរីជាច្រើនព្រោងព្រាតពាសពេញ និងជុំវិញក្រុង។ ទោះជាយ៉ាងណា ភាពប្រណីតទាំងនេះក៏មានភ្ជាប់មកផងដែរនូវផលវិបាកនានា ដូចជា បឹងបួក្នុងក្រុងត្រូវបានលុបបំពេញដោយខ្សាច់ អ្នកក្រីក្រត្រូវបានបណ្តេញចេញពីកណ្តាលក្រុង ទីសាធារណៈមានការរិតត្បិតលើការប្រើប្រាស់ និង អគារប្រវត្តិសាស្ត្រនិងការចងចាំរបស់វាត្រូវបានបាត់បង់ជាដើម។

*វិញ្ញាណកធានី* ពិនិត្យលើទីក្រុង ក៏ដូចជាធនធានមនុស្សនិងវប្បធម៌របស់ទីក្រុង តាមរយៈការស្រាវជ្រាវនិងស្នាដៃសិល្បៈ ដែលផ្តោតអាទិភាពលើការស្វែងយល់ និងមនសិការរបស់មនុស្ស និងអោយតម្លៃដល់ទីក្រុងក្នុងនាមជាតួអង្គដ៏មានជីវិតនិងសកម្ម។ តាមរយៈការតាំងពិព័រណ៍និងព្រឹត្តិការណ៍នៅតាមទីសាធារណៈ សហគមន៍ និងកន្លែងឯកជននានាក្នុងរាជធានីភ្នំពេញ គម្រោងនេះមានគោលបំណងប្រាស្រ័យទាក់ទង និងភ្ញោចវិញ្ញាណរបស់ទស្សនិកជននានាដែលជាប្រជាជនក្នុងក្រុង អំពីស្ថានភាពដ៏សំខាន់បច្ចុប្បន្ននៃទីក្រុងនេះ និងភាពតស៊ូអត់ធន់របស់វា ។

***Sensing the Capital*** is a multi-exhibition and event project that proposes two key ideas: *Sense* and *Capital*, as an approach to investigate and understand Phnom Penh city as well as resources that intersect within it, crossing its border, and hovering its margin, across multi-discipline including art, culture, architecture, and urbanism, through the activation and the use of sensorium or the senses of both the spectators and the city.

As Cambodia adopts neoliberal metropolitanism and increasingly participates in the globalised economy, Phnom Penh has gone through a rapid and imbalanced transformation of its urban landscape and structure, migration and population growth, and environmental ecology. Over the last decade alone, Phnom Penh has witnessed numerous high-rises, shopping malls, apartment complexes and gated housing communities sprouting across the city centre and surrounding areas. However, these luxuries have also come with consequences: city lakes being filled up with sand, urban poor being evicted, public spaces being squeezed up, and historical buildings and their associated memories being demolished.

***Sensing the Capital*** considers Phnom Penh as well as its human and cultural capital through urban research and artistic propositions that foreground human sensibility and consciousness and the city as a living and active agent. Through multiple exhibitions and events that take place at various Phnom Penh's public, communal and private spaces, the project aims to engage with different groups of urban residents to sense the critical state of the city and its persistent resilience.


រៀបចំដោយ
Organised by

Sa Sa Art
THE VANN MOLYVANN PROJECT

ឧបត្ថម្ភដោយ
Supported by

KHMER ARCHITECTURE TOURS
SAC Space for Architecture Cambodia
WORLD MONUMENTS FUND

១ **ពិព័រណ៍ «ពង្សប្រវត្តិតំបន់បាសាក់»** ដោយ ប៉ែន សិរីបញ្ញា ជាមួយ ឈុំ ផានិត
សម្ពោធ៖ ២៥ ឧសភា ២០១៧ ម៉ោង ៦-៨ យប់
ពិព័រណ៍៖ ២៦-៣១ ឧសភា ២០១៧ ជារៀងរាល់ថ្ងៃ ម៉ោង ២-៦ ល្ងាច
ទីកន្លែង៖ គម្រោងសិល្បៈស-ស នៅអគារប៊ូលឌីង

២ **ស្នាដៃសម្តែងសហសម័យ និងការបញ្ចាំងខ្សែភាពយន្ត «កោះពេជ្រ»**
ដោយ យ៉ុន ដាវី, នូ សំណាង និង ជូ ដាវី
កាលបរិច្ឆេទ៖ ២៦ ឧសភា ២០១៧ ម៉ោង ៥:៣០-៧:៤៥ យប់
ទីកន្លែង៖ លើដំបូលអគារប៊ូលឌីង

៣ **ពិព័រណ៍ «ក្រាញនៀល»**
ដោយ អេង រិទ្ធច័ន្ទដាណែត, ម៉ុក សំបូរ, សៅ ស្រីម៉ៅ, សុខ ចាន់រ៉ាដូ និង តាន់ វត្តី
សម្ពោធ៖ ២៨ ឧសភា ២០១៧ ម៉ោង ៦-៨ យប់
ពិព័រណ៍៖ ៣១ ឧសភា - ១៨ មិថុនា, ពុធ-សៅរ៍ ម៉ោង ១០ព្រឹក-៦ល្ងាច
ទីកន្លែង៖ ទីតាំងថ្មីនៃគម្រោងសិល្បៈស-ស ផ្ទះ ៤៧ ផ្លូវ ៣៥០ (កែងផ្លូវ ៩៥)

៤ **ពិព័រណ៍ «ពហុកីឡដ្ឋានជាតិ៖ កេរ្តិ៍ដំណែល និងទស្សនៈវិស័យ»**
ដោយ គម្រោង វណ្ណ ម៉ូលីវណ្ណ និងសហការី
សម្ពោធ៖ ២១ មិថុនា ២០១៧ ម៉ោង ៥ ល្ងាច (នឹងបញ្ជាក់ឆាប់ៗ)
ពិព័រណ៍៖ ២១-២៧ មិថុនា (នឹងបញ្ជាក់ឆាប់ៗ)
ទីកន្លែង៖ ពហុកីឡដ្ឋានជាតិអូឡាំពិក (នឹងបញ្ជាក់ឆាប់ៗ)

៥ **ដំណើរទស្សនា និងកម្មវិធីស្តីពីរោងកុន** ដោយ គម្រោងរោងកុន
ដំណើរទស្សនា៖ ២៤ មិថុនា ២០១៧ ម៉ោង ៨:៣០ ព្រឹក (ភាសាខ្មែរ)
និងម៉ោង ៩ ព្រឹក (ភាសាអង់គ្លេស)
សូមកក់កន្លែងតាមរយៈ៖ info@roungkonproject.com
កម្មវិធី៖ ២៤ មិថុនា ម៉ោង ៦ ល្ងាច (ទីកន្លែងនឹងបញ្ជាក់ឆាប់ៗ)

៦ **សិក្ខាសាលាសិក្សាពីរាជធានីភ្នំពេញតាមរយៈផែនទី** ដោយ ប៉ែន សិរីបញ្ញា
កាលបរិច្ឆេទ៖ ២៥ មិថុនា ២០១៧ ម៉ោង ១០ ព្រឹក - ១២ ថ្ងៃត្រង់
ទីកន្លែង៖ កន្លែងខ្ញុំ ផ្ទះ ១១Z ផ្លូវ ៣៦០

1 **"Genealogy of Bassac" Exhibition**
by Pen Sereypagna with Chhum Phanith
Opening: 25 May 2017, 6-8pm
Exhibition period: 26 – 31 May, everyday 2-6pm
Venue: Sa Sa Art Projects, the White Building

2 **Contemporary Performance & "Diamond Island" Film**
by Yon Davy, Nou Samnang and Davy Chou
Date: 26 May 2017, 5:30-7:45pm
Venue: Rooftop of the White Building

3 **"Kraanh Norneal" Exhibition**
by Eng Rithchandaneth, Mok Sombo, Sao Sreymao,
Sok Chanrado and Tan Vatey
Opening: 28 May 2017, 6-8pm
Exhibition period: 31 May – 18 June, Wed-Sat 10am-6pm
Venue: New space of Sa Sa Art Projects, #47, St 350 (off St 95)

4 **"The National Sports Complex: Legacy and Vision" Exhibition**
by Vann Molyvann Project and collaborators
Opening: 21 June 2017, 5pm (tbc)
Exhibition period: 21 – 27 June (tbc)
Venue: Olympic Stadium (tbc)

5 **Roungkon Project Tour & Event**
by Roungkon Project
Guided tour: 24 June 2017, 8:30am (Khmer) & 9am (English)
Booking: info@roungkonproject.com
Event: 24 June, 6pm (venue tbc)

6 **Studying Phnom Penh through Maps: A Workshop**
by Pen Sereypagna
Date: 25 June 2017, 10am-12pm
Venue: Kon Len Khnhom, #11Z, Street 360

ព័ត៌មានបន្ថែម / More information:
info@sasaart.info, 092 961 974, 092 787 867